ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សតាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣៣១
ចុះថ្ងៃទី ០៧-០៤-២០១១
សាលដីកា
លេខ ៖ ៤១ "ក្រ.III.ស"
ចុះថ្ងៃទី ១៩-០៦-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

៧៧៧ ★ ៣៣៣

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

## ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted]

## ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៣៣១ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១១ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted]ហេង ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ៥នាក់ ទោសគ្មានពីមុន។

មានលោក [redacted]ទ្ធារិទ្ធ ជាមេធាវីការពារ។

<u>ជាប់ចោទពីបទ:</u> ប្លន់ ប្រព្រឹត្តនៅភូមិក្រាំងបន្ទាយ ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សៀម ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ និងធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិក្រាំងបន្ទាយ ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ។

## ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ១៩ និង០០នាទី មានក្រុមចោរមួយក្រុមប្រដាប់ដោយអាវុធអាកា៤៧ ធ្វើជាមធ្យោបាយ បានទៅធ្វើសកម្មភាពប្លន់នៅផ្ទះជនរងគ្រោះឈ្មោះ [redacted] សៀម





Scanned with CamScanner

ស្ថិតនៅភូមិក្រាំងបន្ទាយ ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ ពួកគេបានវាយម្ចាស់ផ្ទះ និងយកទ្រព្យសម្បត្តិរួមមាន ប្រាក់រៀលចំនួន ៤០០០០០រៀល, ប្រាក់ដុល្លារចំនួន ៣០ដុល្លារ និងកាតទូរស័ព្ទគិតជាប្រាក់ចំនួន ៤០ដុល្លាអាមេរិក។ ក្រោយពីធ្វើសកម្មភាពប្លន់រួច សមត្ថកិច្ចបានចុះស្រាវជ្រាវស្តាប់ចម្លើយសាក្សី ចម្លើយជនរងគ្រោះ និងការពិនិត្យកន្លែងកើតហេតុ បានរកឃើញសំបកគ្រាប់ចំនួន ០១ ដែលបន្សល់ទុកនៅនឹងកន្លែង និងឈានទៅកំណត់មុខសញ្ញាជនសង្ស័យដែលបានធ្វើសកម្មភាពប្លន់មានឈ្មោះ[redacted]វ៉ាន់ មានទីលំនៅភូមិប្រសូត្រថ្មី ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ និងឈ្មោះ [redacted] ហេង មានទីលំនៅភូមិទឹកថ្លា ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ហើយសមត្ថកិច្ចកសាងសំណុំរឿងខាងលើបញ្ជូនមកអយ្យការអមសាលាដំបូង ខេត្តតាកែវ

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៣ ខ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូង ខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោស:

ក- ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ ៤២ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១០។

ខ- ឈ្មោះ [redacted] វ៉ាន់ ហៅ កុសល ភេទប្រុស អាយុ ៣២ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន។

ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិក្រាំងបន្ទាយ ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- សំណង: បង្គាប់ឲ្យឈ្មោះ [redacted] ហេង និងឈ្មោះ [redacted] វ៉ាន់ ហៅ កុសល រួមគ្នាសងប្រាក់ចំនួន ៤០ម៉ឺនរៀល ប្រាក់ដុល្លាអាមេរិកចំនួន ៣០ដុល្លារ និងថ្លៃកាតទូរស័ព្ទចំនួន ៤០ដុល្លារអាមេរិក ទៅដើមបណ្តឹងឈ្មោះ[redacted]សៀម គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

៣- វត្ថុតាង: សំបកគ្រាប់ AK ប្រវែង ៤សម មានលេខ ៧៤១៦ ត្រូវរឹបអូស និងបំផ្លាញចោល។

៤- សម្រេចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ឃុំខ្លួនឈ្មោះ[redacted]វ៉ាន់ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះ។

៥- សាលក្រមនេះជំនុំជម្រះជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហេង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១១ របស់ឈ្មោះ៖



Scanned with CamScanner

[redacted] ហេង ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៣ ខ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តតាកែវ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។
- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសោមសៀមបានឆ្លើយនៅសាលាដំបូងខេត្តតាកែវ

ជនជាប់ចោទឈ្មោះ [redacted] ហេង ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍ដោយខ្លួនមិនបានប្រព្រឹត្ត ខ្លួនអត់ដែលស្គាល់ឈ្មោះ [redacted] វ៉ាន់ ទេ ថ្ងៃកើតហេតុខ្លួនអត់បានដឹងទេ ការទំនាក់ទំនងជាមួយឈ្មោះ [redacted] វ៉ាន់ គឺទើបតែស្គាល់ ហើយប្រពន្ធឈ្មោះ [redacted] វ៉ាន់ ខ្លួនអត់ស្គាល់ទេ ឯដើមបណ្តឹងក៏ខ្លួនអត់ស្គាល់ដែរ។ ផ្ទះខ្លួននៅឆ្ងាយប្រហែល ៧ ទៅ ៨គីឡូម៉ែត្រ ពីគ្នា ប្រពន្ធខ្លួនលក់ស៊ុបមានគេមកហូបច្រើន។ ថ្ងៃកើតហេតុខ្លួនមិនចាំទេ ខ្លួនចាំតែថ្ងៃហ្នឹងមានគេបញ្ជាំងកុននៅមុខផ្ទះខ្លួន, ប្រហែលម៉ោងជាង ៦ ខ្លួនបានទៅជួយលើកផ្ទាំងប៉ាណូកុនជាមួយឈ្មោះ សារ៉ុម ហើយម៉ោង ៧ ត្រឡប់មកផ្ទះរហូត។ ចំពោះកាំភ្លើងខ្លួនអត់ដឹងទេ។ ខ្លួនមិនមានភស្តុតាងបញ្ជាក់ទេ ព្រោះខ្លួនមិនបានប្រព្រឹត្ត បើខ្លួនបានប្រព្រឹត្តមែនខ្លួននឹងទទួលទោសនៅមុខតុលាការ ខ្លួនមិនគេចវេសទេ។ ឈ្មោះ កុសល និងឈ្មោះ វ៉ាន់ ខ្លួនស្គាល់ពេលគាត់មកញុំាស៊ុបប៉ុណ្ណោះ មិនដែលមានទំនាក់ទំនងអីជាមួយគាត់ទេ។ សំណូមពរ សុំតុលាការរកយុត្តិធម៌ឲ្យខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

យល់ថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ តាមមាត្រា ៣៧៥ មាត្រា ៣៨២ នៃក្រមនិតិវិធីព្រហ្មទណ្ឌ។ មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ហេង ដូចបទចោទប្រកាន់របស់អយ្យការសាលាដំបូង (ចម្លើយសាក្សីឈ្មោះ [redacted] ម៉ៅ ជាប្រពន្ធ ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ បញ្ជាក់ថា ប្តីខ្លួន និងឈ្មោះ [redacted] ហេង បានជជែកគ្នាពីរឿងកាំភ្លើងថា ទុកនៅផ្ទះបងឡាវ, ចម្លើយសាក្សីឈ្មោះ [redacted] ចំរើន បញ្ជាក់ថា ឃើញឈ្មោះ [redacted] វ៉ាន់ យកកាំភ្លើងពីដើមដាក់ក្នុង កាបូបផ្ញើខ្លួនទុក តែខ្លួនមិនហ៊ានទទួល, សាក្សីឈ្មោះ [redacted] រ៉ុម និងឈ្មោះ [redacted] សុខ ក៏បានបញ្ជាក់ដូច សាក្សីឈ្មោះ [redacted] ចំរើន ដែរ និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងវត្ថុតាង)។ ចម្លើយរបស់ជនជាប់ចោទបដិសេធពុំមានមូលដ្ឋានច្បាស់លាស់។ សាលក្រមរបស់សាលាដំបូងសម្រេចមកនេះមានសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវហើយគួរ តម្កល់ ដោយគ្រាន់តែសុំក្រុមប្រឹក្សាពិចារណា តាមមាត្រា ១០ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ យោងតាមមាត្រា ១០ និងមាត្រា ៣៥៧ នៃក្រម



Scanned with CamScanner

ព្រហ្មទណ្ឌ។ តាមការអះអាងរបស់កូនក្តីខ្លួនបានបដិសេធតាំងពីដំណាក់កាលដំបូងថា គាត់មិនបានប្រព្រឹត្តទេ ហើយមានសាក្សីមួយចំនួនបញ្ជាក់ថា នៅថ្ងៃកើតហេតុ គឺមានភាពច្របូកច្របល់មិនអាចសន្និដ្ឋានបានថាអ្នកណាជាអ្នកប្រព្រឹត្តទេ។ នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ៧ និង៣០នាទី យប់ ជាថ្ងៃកើតហេតុ តែតាមសាលក្រមត្រង់ចំណុចសវនាការ ឈ្មោះ [redacted] ផុន ឈ្មោះ [redacted] សារុន ឈ្មោះ [redacted] សាត ជាក្រុមប្រឹក្សាឃុំឆ្លើយថា នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១០ ម៉ោង ៧ជាងយប់ ខ្លួនពិតជាបានឃើញឈ្មោះ [redacted] ហេង តែមិនដឹងស្លៀកពាក់អីទេ ហើយឈ្មោះ [redacted] ណាយ បានឆ្លើយថា ឈ្មោះ [redacted] ហេង គាត់បានទៅខ្ចីគុននៅម៉ោងជាង ៧យប់ ដូចគ្នាឃើញឈ្មោះ [redacted] ហេង នៅផ្ទះ, ឈ្មោះ [redacted] សារុន ឆ្លើយថា ឈ្មោះ [redacted] ហេង គាត់នៅផ្ទះ។ តាមមាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ សូមក្រុមប្រឹក្សាសម្រេចលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនផង។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ហេង ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- តាមចម្លើយជនជាប់ចោទថា កាលពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១០ ជាថ្ងៃកើតហេតុ ខ្លួននៅផ្ទះហេតុពុំបានចេញទៅណាទេ ពេលនោះខ្លួនបានទទួល ទូរស័ព្ទពី [redacted] វ៉ាន់ ហៅ កុសល សួរខ្លួនថា មានអ្នកណាទិញម៉ូតូអត់ពន្ធ ឬទេ? បន្ទាប់មក កុសល ឌុប ប្រពន្ធរបស់គេឈ្មោះ [redacted] ម៉ៅ មកផ្ទះខ្លួន។ លុះដល់ម៉ោង ២ និង៣០នាទី ឈ្មោះ កុសល ឌុបមនុស្សម្នាក់ផ្សេងទៀតមករកខ្ចីលុយខ្លួន ១០ម៉ឺនរៀល។ ខ្លួនមិនស្គាល់មនុស្សនោះទេ។ ថ្ងៃនោះនៅម៉ោង ៤ល្ងាច ខ្លួនយក គោទៅមើលនៅក្នុងវត្តអង្គរុន រហូតម៉ោង ៦ល្ងាចទើបមកវិញ។ យប់នោះគេបញ្ចាំងកុននៅជិតផ្ទះខ្លួន, ខ្លួន នៅអង្គុយមើលកុនជាមួយប្រពន្ធកូនរហូតដល់ចប់នៅម៉ោង ១១យប់។ ខ្លួនពុំបានប្លន់ និងពុំបានរៀបចំគម្រោងប្លន់តាមទូរស័ព្ទជាមួយ កុសល ទេ។ ខ្លួនមិនស្គាល់ឈ្មោះ ទូច ទេ។

២-១- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ ហៅ កុសល នៅចៅក្រមស៊ើបសួរថា នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ៤ ខ្លួនទៅផ្ទះឈ្មោះ ទូច ផឹកដល់ម៉ោង ៧យប់ រួចទៅកាប់គោជាមួយឈ្មោះ



Scanned with CamScanner

ទូច រួចទៅផឹកវិញ ជាមួយឈ្មោះ ម៉ី និង ២នាក់ ទៀតមិនស្គាល់ឈ្មោះ, លុះព្រឹកឡើងទើបត្រឡប់ទៅផ្ទះនៅជាមួយប្រពន្ធវិញ។ ចំពោះការប្លន់នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១០ ខ្លួនពុំបានដឹង និងពុំបានចូលរួមទេ។

៣- តាមចម្លើយអ្នកស្រី [redacted] ម៉ៅ ជាប្រពន្ធជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ ហៅ កុសល ថា ថ្ងៃខែមិនចាំខ្លួន និងប្តី (កុសល) ទៅដេកផ្ទះឈ្មោះ ទូច ហៅ [redacted] ចំរើន នៅភូមិទួលត្បែង ឃុំតាភេម ស្រុកត្រាំកក់ស្រាប់តែឃើញឈ្មោះ [redacted] ហេង ទៅដល់ដែរ។ ពេលនោះប្តីខ្លួន (កុសល) សួរថា រកស៊ីបានទេ? ឈ្មោះ [redacted] ហេង ថា មិនសូវបានទេ, តែឥលូវបងឯងគិតធ្វើជាមួយខ្ញុំទៀតទេ? ឈ្មោះ កុសល សួរថា នៅឯណា? ឈ្មោះ ហេង ថា នៅខាងលិចអង្គត្នោត គេមានលុយច្រើនណាស់, កុសល សួរពីកម្លាំងមានទេ? ហេង ថា ពួកគាត់មកពីកំពតសាហាវណាស់ ហើយក៏នាំគ្នាទៅនិយាយឆ្ងាយពីខ្លួន។ មួយសន្ទុះក្រោយខ្លួនទៅជិតឮប្តីខ្លួនថាកាំភ្លើងទុកនៅផ្ទះបងឡាវ ជិតបាចុង ០១ដើម នៅព្រៃតាខាប មានឈ្មោះ វុធ ម្នាក់ទៀត។ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១០ ប្តីខ្លួននាំខ្លួនទៅលេងផ្ទះឈ្មោះ ហេង ដោយថា ឈ្មោះ ហេង គេឲ្យទៅលេង។ លុះទៅដល់ប្តីខ្លួនចូលទៅក្នុងផ្ទះបាត់ប្រហែល ០១ម៉ោង ទើបឃើញឈ្មោះ ហេង និងប្តីខ្លួនចេញមកវិញ ហើយខ្លួនក៏ ត្រឡប់មកផ្ទះវិញ ដល់ពាក់កណ្តាលផ្លូវខ្លួនសួរប្តីខ្លួន គាត់ថា យប់នេះឈ្មោះ ហេង ហៅទៅធ្វើនៅក្រាំងបន្ទាយ ហើយពេលនោះមិនដូចលើកមុនដែលធ្វើនៅអង្គត្នោតទេ។ លុះដល់ម៉ោង ១១ ប្តីខ្លួនក៏ត្រឡប់ទៅផ្ទះ [redacted] ហេង វិញ។

៣-១- សាក្សីឈ្មោះ [redacted] ចំរើន នៅភូមិខ្នានែថា រឿងហេតុកើតនៅភូមិក្រាំងបន្ទាយ ខ្លួនពុំដឹងទេ តែរយៈ ៣ឆ្នាំ កន្លងទៅ មានមនុស្សបីនាក់យកកាំភ្លើងទៅផ្ញើនៅផ្ទះខ្លួន តែខ្លួនមិនឲ្យផ្ញើ។ អ្នកផ្ញើមានឈ្មោះ ឆុន នៅភូមិទឹកក្រហម និងឈ្មោះ កុសល។

៣-២- សាក្សីឈ្មោះ [redacted] រ៉ុម ថា នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១០ ខ្លួនទៅលេងផ្ទះឈ្មោះ ចំរើន នៅភូមិខ្នានែ ខ្លួនសួរថា ពួកអស់នោះដែលមក ឬទេ? ឈ្មោះ ចំរើន ថា មិនដែលមកទេ វានៅតែផ្ទះអា ហេង [redacted] ហេង) អង្គរុន ហើយប៉ុន្មានថ្ងៃមុននេះ អាសល និង អាហេង យកកាំភ្លើង AK ពីរដើមមកផ្ញើដែរ តែឈ្មោះ ចំរើន មិនឲ្យផ្ញើ។

៣-៣- សាក្សីឈ្មោះ [redacted] សុខ ថា កាលពីថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១០ ខ្លួនទៅលេងផ្ទះ ចំរើន ជាបង នៅភូមិខ្នានែ, ឈ្មោះ ចំរើន ថា អាហេង, អាកុសល ត្រូវគ្នាណាស់ ដេកនៅតែអង្គរុន ហើយពួកវាមានកាំភ្លើង AK ពីរដើម ថ្ងៃមុនពួកវាយកមកទុកនៅផ្ទះគាត់ តែគាត់មិនឲ្យទុក។

៤- តាមចម្លើយសាក្សីទាំងអស់នេះអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោ [redacted] ហេង ពិតជាបានធ្វើសកម្មភាពប្លន់ផ្ទះជនរងគ្រោះនៅភូមិក្រាំងបន្ទាយមែន។ ដូច្នេះ ចម្លើយជនជាប់ចោទដែលបានឆ្លើយបដិសេធនោះគ្រាន់តែជាចម្លើយដោះសា ក្នុងបំណងគេចវេះពីការទទួលខុសត្រូវចំពោះមុខច្បាប់ប៉ុណ្ណោះ។

៥- មានភស្តុតាងដាក់បន្ទុកបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទ លួចដោយហិង្សា ប្រព្រឹត្តនៅភូមិក្រាំងបន្ទាយ ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១០ បទល្មើសមាន ចែង



Scanned with CamScanner

និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ គួរកែបទចោទឡើងវិញ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ០៣ ខ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តតាកែវ សម្រេចមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែបទចោទ គួរកែប្រែដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១១ របស់ឈ្មោះ[redacted] ហេង ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៣ ខ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការ លើកលែងតែបទចោទនៅចំណុចទី ១ លើជនជាប់ចោទឈ្មោះ [redacted] ហេង ត្រូវកែប្រែពីបទ ប្លន់ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទ លួចដោយហិង្សា តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ វិញ។

ក្រៅពីនេះទុកនៅដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] | [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៤ ខែ ០៤ ឆ្នាំ ២០១៤

ក្រឡាបញ្ជី



Scanned with CamScanner